ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី២ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសលើកទី២ សម្រាប់ឆ្នាំ២០២១ នៅបន្ទប់ប្រជុំ"ខ"នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម យិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ដោយមានការចូលរួមពីសមាជិក សមាជិកាថ្នាក់បច្ចេកទេស អន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធមួយចំនួន ចូលរួមតាមរយៈវីអូខនហ្វើរេន(Blue Jeans)។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ជម្រាបជូនសមាជិក សមាជិកាឱ្យយល់ដឹងពីវឌ្ឍនភាពនៃការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់នៅភូមិភាគឧត្តរនៃប្រទេសកម្ពុជា។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម យិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកាក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ដែលបានអញ្ជើញចូលរួមផ្ទាល់ និងតាមរយៈវីដេអូខនហ្វើរេន។ នាឱកាសនោះ ឯកឧត្តមបានជម្រាបជូនសមាជិកឱ្យបានយល់ថា ទោះបីបច្ចុប្បន្នយើងកំពុងព្រួយបារម្ភចំពោះបញ្ហាជំងឺកូវីត-១៩ កំពុងតែរាតត្បាតទូទាំងពិភពលោកយ៉ាងណាក៏ដោយ ក៏យើងមិនអាចបន្ធូរចំពោះបញ្ហាអេដស៍នេះដែរ យើងនៅតែបន្តការតាមដាន ត្រួតពិនិត្យ និងការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដូច្នេះហើយទើបសិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសត្រូវរៀបចំជាប្រចាំរៀងរាល់មួយខែម្តង ដើម្បីឱ្យការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ អនុវត្តមានប្រសិទ្ធភាពក្នុងការលុបបំបាត់ការឆ្លងថ្មី គ្មានការស្លាប់ដោយសារជំងឺអេដស៍ និងគ្មានការរើសអើងដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ម៉្យាងទៀតគឺបានចែករំលែកនូវការយល់ដឹងក៏ដូចជាបទពិសោធន៍ពីគ្នាទៅវិញទៅមក ព្រមទាំងសំណូមពរនានា ឬក៏មានបញ្ហាទាក់ទងនឹងបញ្ហាអេដស៍លើកយកមកពិភាក្សាដើម្បីរកដំណោះស្រាយរួមគ្នា។

បន្ទាប់មកលោកស្រី ប្រាជ្ញ ស៊ីណាត អ្នកសម្របសម្រួលនៃអង្គការ វ៉ាក់ បានធ្វើបទបង្ហាញអំពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ដូចជា៖ អប់រំពីជំងឺអេដស៍ ធ្វើតេស្តឈាមចុងម្រាមដៃរកមេរោគអេដស៍ មេរោគស្វាយ ដោយរក្សាការសម្ងាត់ បញ្ជូនទៅទទួលសេវាព្យាបាល ថែទាំ និងផ្តល់ស្រោមអនាម័យ ទឹករំអិល ដោយឥតគិតថ្លៃដល់ស្ត្រីធ្វើការនៅសេវាកម្សាន្ត ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមស្រីស្រស់ នៅកន្លែងធ្វើការផ្ទាល់របស់ពួកគេ នៅកន្លែងសេវាគ្រឹះស្ថានកម្សាន្ត និងនៅកន្លែងប្រមូលផ្តុំផ្សេងៗទៀតជាច្រើន ដើម្បីបង្កើនការស្វែងរក និងព្យាបាលករណីអេដស៍ថ្មីឱ្យបានទាន់ពេលវេលា។

សកម្មភាពដែលបានអនុវត្តមាន៨ខេត្តគឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងកំពង់ធំ ដែលបានធ្វើទៅលើស្ត្រីធ្វើការនៅសេវាកម្សាន្តសប្បាយ ក្រុមបុរសរួមភេទ

ជាមួយបុរស និងក្រុមស្រីស្រស់ សរុបជាងពីរម៉ឺននាក់ ជាទូទៅបានរកឃើញ មានវិជ្ជមាន២ករណី ជាមធ្យមក្នុងមួយថ្ងៃសម្រាប់ក្រុមប្រឈម។ តាមលទ្ធផលនៃការប៉ាន់ប្រមាណអំពីលក្ខណៈប្រឈមក្នុងកំឡុងឆ្នាំ២០២០ ក្នុងចំណោមបុរសរួមភេទជាមួយបុរសចំនួន៦៨៣នាក់ មានអត្រាផ្ទុកមេរោគអេដស៍៧៥.៧% អ្នកបំប្លែងភេទចំនួន១០០នាក់មានអត្រាផ្ទុកមេរោគអេដស៍១១.១% និងស្ត្រីបំរើសេវាកម្សាន្តឯករាជ្យចំនួន ១១៩នាក់ មានអត្រាផ្ទុកមេរោគអេដស៍១៣.២%។

ទន្ទឹមនឹងនោះក៏បានរកឃើញថា មានកត្តាមួយចំនួនផ្សេងទៀតដែលជំរុញឱ្យក្រុមបុរសរួមភេទជាមួយបុរសប្រឈមនឹងការឆ្លងមេរោគអេដស៍មានការកើនឡើង ដោយសារឥរិយាបទប្រព្រឹត្តរបស់គាត់ គឺគាត់ដើរតួរជាស្ត្រី ហើយធ្វើការទំនាក់ទំនងគ្នាតាមរយៈ Smart phone ដូចជា App, Face Book, Twitter, Instagram, Snapchat ។ល។

តាមរបាយការណ៍ចាប់ពីត្រីមាសទី២ ឆ្នាំ២០១៨ ដល់ត្រីមាសទី៤ ឆ្នាំ២០២០ ករណីវិជ្ជមានបានរកឃើញតាមរយៈការព្យាបាល និងរបៀបនៃការផ្តល់សេវាដូចជា៖

- ផ្តល់សេវាតាមសហគមន៍ រកឃើញបានចំនួន៥៩៤នាក់
- គ្លីនិកវ៉ាក់ រកឃើញបានចំនួន១០៨នាក់
- តាមរយៈPDI+ រកឃើញបានចំនួន៤៨នាក់
- តាមប្រព័ន្ធផ្សព្វផ្សាយរកឃើញ១៥២នាក់

ការអប់រំផ្សព្វផ្សាយតាមបណ្តាញសង្គមមាន៣ទំរង់៖

- អប់រំដោយផ្ទាល់តាមបណ្តាញសហគមន៍
- អប់រំតាមលក្ខណៈសង្គមដោយប្រើការផ្សព្វផ្សាយទីផ្សារតាមរយៈបច្ចេកវិទ្យា
- អប់រំតាមកន្លែង និម្មិត ឬការភ្ជាប់បណ្តាញសង្គម

តាមលទ្ធផលនៃការសិក្សាពីហេតុផលលើឥរិយាបទប្រឈមនឹងការឆ្លងមេរោគអេដស៍ គឺមិនប្រើស្រោមអនាម័យដោយទុកចិត្តដៃគូ ក្នុងនោះបានបញ្ជាក់ថា៖

- ដៃគូប្រមាណ៥០% ប្រទ្បំថាគ្មានឆ្លងមេរោគអេដស៍ទេនៅពេលរួមភេទ
- មានការយល់ដឹងពីបញ្ហាអេដស៍ឆ្លងតាមរន្ធគូទមាន១៥%
- ការទិញលក់សេវាផ្លូវភេទមាន៥%
- មានដៃគូច្រើនមិនច្បាស់លាស់មាន១០%
- និងដៃគូចៃដន្យមាន២០% ។

បញ្ហាប្រឈម និងមេរៀនបទពិសោធន៍

- ក្រុមបុរសរួមភេទជាមួយបុរសភាគច្រើនមិនមានស្រោមអនាម័យជាប់ខ្លួន
- ភាគច្រើននៃក្រុមនេះជាអតិថិជនវ័យក្មេងដែលបានធ្វើការទំនាក់ទំនងតាមបណ្តាញសង្គម
- គាត់មានទំនោរផ្លូវភេទដោយមិនបានប្រើមធ្យោបាយការពារការឆ្លងមេរោគអេដស៍ ឬជំងឺឆ្លងផ្សេងៗទៀត
- ក្រុមបុរសរួមភេទជាមួយបុរសវ័យក្មេងមួយចំនួនមានការជួបជុំនៅតាមផ្ទះសំណាក់ និងអាចមានការរួមភេទបូកជាក្រុមដោយមិនបានការពារ។

ដំណោះស្រាយ

- ស្នើដាក់ទីតាំងស្រោមអនាម័យដែលអាចឱ្យអតិថិជនទៅយកបាននៅពេលយប់ ឬនៅពេលត្រូវការដែលមិនចាំបាច់ត្រូវការទំនាក់ទំនងជាមួយក្រុមការងារ
- បង្កើនការអប់រំផ្សព្វផ្សាយតាមបណ្តាញសង្គម និងនៅតាមសហគមន៍ ឬសេវាកម្សាន្ត បិតបដាអប់រំផ្សព្វផ្សាយ
- សហការជាមួយអាជ្ញាធរដែនដី និងដៃគូនានាដើម្បីសម្របសម្រួលការងារក្នុងសហគមន៍

ផែនការបន្ទាប់

- បង្កើនការផ្សព្វផ្សាយក្នុងប្រព័ន្ធបណ្តាញសង្គមជាមួយកម្មវិធីថ្នាក់ជាតិការពារខ្លួនអ្នក
- បង្កើតសារ និងវីដេអូផ្សព្វផ្សាយក្នុងបណ្តាញសង្គម
- ជ្រើសរើសតំណាងតារាដែលមានឥទ្ធិពល និងមានប្រជាប្រិយភាពសម្រាប់កម្មវិធីសំភាសន៍ និងផ្សព្វផ្សាយ
- បន្តស្វែងរកក្រុមប្រឈមតាមបណ្តាញសង្គម
- បង្កើនវិធីសាស្រ្ត Pre-Exposure Prophylaxis(PrEP) និងពង្រីកឱ្យបានទូលំទូលាយ។
- លើកកំពស់ការផ្សព្វផ្សាយប្រសិទ្ធភាពនៃស្រោមអនាម័យ។

មតិយោបល់៖

- តំណាងខេត្តត្បូងឃ្មុំ៖ នៅក្នុងខេត្តមានអង្គការ MHC បានធ្វើការងារទាក់ទងនឹងក្រុមបុរសរួមភេទជាមួយបុរស ដែលមានចំនួន៧២០នាក់ ក្នុងនោះអ្នកផ្ទុកមេរោគអេដស៍មានចំនួន២៤នាក់ និងស្រីស្រស់មានចំនួន ១៣១នាក់។ ហើយអង្គការនេះបានអនុវត្តគ្របដណ្តប់ទៅលើស្រុកចំនួនបីទៀតគឺ ស្រុកសួង មេមត់ និងអូរាំងឪ ក្នុងចំណោមស្រុកទាំងបី មានស្រុកពីរដែលមានហានិភ័យខ្ពស់ គឺស្រុកសួង និងស្រុកមេមត់។

- តំណាងខេត្តបាត់ដំបង៖ ក្នុងមួយឆ្នាំបានរកឃើញអ្នកផ្ទុកមេរោគអេដស៍ប្រហែល៣០នាក់។ ពួកគាត់ច្រើនមានដៃគូច្រើន រីឯក្រុមបុរសស្រលាញ់បុរសធ្វើការតាមក្រុមហ៊ុននានា ច្រើនមានដៃគូនៅកន្លែងធ្វើការងារ ឬក៏ជាមួយមេរបស់គាត់ ដែលជាបញ្ហាពិបាកក្នុងការបង្ហាញមុខ។ មួយផ្នែកទៀតគឺគាត់មិនចង់ប្រើស្រោមអនាម័យ ដោយគាត់យល់ថាការប្រើប្រាស់ PrEP វាអាចការពារបាន
- តំណាងខេត្តកំពត៖ បានប្តេជ្ញាចិត្តអនុវត្តការងារអេដស៍ដើម្បីសម្រេចគោលដៅរបស់រដ្ឋាភិបាល
- តំណាងក្រសួងកសិកម្ម៖ សំណូមពរពង្រឹងការអនុវត្តច្បាប់អេដស៍ ទៅលើអ្នកដែលប្រព្រឹត្តល្មើសនឹងច្បាប់អេដស៍ បើមិនដូចនោះទេគាត់នឹងចម្លងទៅអ្នកដទៃជាពិសេសក្រុមបុរសរួមភេទជាមួយបុរស។

បន្ទាប់មក **ឯកឧត្តម** អគ្គលេខាធិការ ប្រធានអង្គប្រជុំបានទទួលយកនូវសំណូមពរ និងការលើកឡើងរបស់សមាជិក សមាជិកា និងបានបន្តថា ទោះជាបច្ចុប្បន្នស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍បានថយចុះក៏ពិតមែន ប៉ុន្តែនៅតែជាបញ្ហាប្រឈមមុខខ្ពស់ដដែលចំពោះក្រុមប្រជាជនគន្លឹះ ពិសេសក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ ដែលអត្រាឆ្លងមេរោគអេដស៍នៅតែកើនឡើងខ្ពស់គួរឱ្យព្រួយបារម្ភ ដូច្នេះក្រុមការងារបង្ការមិនអាចបន្ធូរដៃបានទេត្រូវតែរកវិធីសាស្ត្រថ្មីៗ និងអន្តរាគមន៍បន្ថែមទៀតដើម្បីឈានទៅសម្រេចគោលដៅនៅឆ្នាំ២០២៥។

ចុងបញ្ចប់ ឯកឧត្តមប្រធាន ក៏បានថ្លែងអំណរគុណចំពោះលោកស្រី ប្រាជ្ញ ស៊ីណាត ដែលបានចែករំលែកនូវបទពិសោធន៍ការងារ និងសមាជិក សមាជិកាទាំងអស់ដែលបានចូលរួមក្នុងអង្គសិក្ខាសាលានាពេលនេះ និងបានកំណត់យកសិក្ខាសាលាលើកក្រោយនៅថ្ងៃពុធ ១៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ។

ថ្ងៃព្រហស្បតិ៍ ០៦រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១

**អ្នកធ្វើរបាយការណ៍**

ស៊ុំ ផល្លា

បានពិនិត្យត្រឹមត្រូវ

**ប្រធាននាយកដ្ឋាន**

**ទាក់ទង និងចលនាប្រភពធនធាន**

ហួត សេរីវឌ្ឍ

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់

**អគ្គលេខាធិការ**

**ឈឹម ឃិនដារ៉េត**